ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល

Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Dec-2014, 15:40
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រ៊ឹម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី១១ / ខែ ធ្នូ / ឆ្នាំ ២០១៤
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ:

# សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីជនជាប់ចោទ នួន ជា**

សុន អរុណ
Victor KOPPE

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

១. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួល"សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំពន្យារពេលឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា" ដាក់នៅថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៤[1] និង"សំណើបន្ទាន់របស់ នួន ជា សុំពេលវេលាបន្ថែមដើម្បី ដាក់សារណាតបទៅនឹងសារណាបបណ្តឹងសាទុក្ខរបស់ សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ដាក់នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៤ ("សំណើរបស់នួនជា")[2] ដែលសំណើនេះ ត្រូវបានសហព្រះរាជអាជ្ញា ដាក់សារណាតបរួមមួយនៅថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៤[3]។

២. អង្គជំនុំជម្រះតុលាការកំពូល ក៏បានទទួលផងដែរនូវ"សំណើបន្ទាន់សុំការពិចារណាឡើងវិញលើការកំណត់ចំនួនទំព័រនៃបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងរឿងក្តី ០០២/០១"របស់ នួន ជា ដែលដាក់នៅថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៤[4] ដែលសហព្រះរាជអាជ្ញា ដាក់សារណាតបនៅថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៤[5]។

## <u>**សាវតារ**</u>

៣. នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានចេញសាលក្រមក្នុងសំណុំរឿង០០២/០១ ("សាលក្រម")[6] ដោយផ្តន្ទាទោស ខៀវ សំផន និង នួន ជា ពីបទឧក្រិដ្ឋប្រឆាំង

---

[1] ឯកសារ F12 ("សំណើសុំពន្យារពេលរបស់ ខៀវ សំផន")។

[2] ឯកសារ F14 ("សំណើសុំពន្យារពេលរបស់ នួន ជា")។

[3] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើបន្ទាន់របស់ នួន ជា និង ខៀវ សំផន សុំពន្យារពេលដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ឯកសារ F12/1 ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៤ ("ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំពន្យារពេល")។

[4] ឯកសារ F13 ("សំណើរបស់ នួន ជា សុំបន្ថែមចំនួនទំព័រ")។

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំបន្ថែមចំនួនទំព័រកំណត់បន្ថែមទៀត ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ឯកសារ F13/1 ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៤ ("ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំបន្ថែមចំនួនទំព័រ")។

[6] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313 ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។

មនុស្សជាតិ ទាក់ទិននឹងការសម្លាប់រង្គាល (រួមមានមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមានការជម្លៀសដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស) និងសម្រេចដាក់ពន្ធនាគារអស់មួយជីវិត[7]។

៤. នៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៤ នួន ជា និង ខៀវ សំផន បានជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមសាលាដំបូងដោយ នួន ជា មានមូលដ្ឋាននៃបណ្ដឹងសាទុក្ខចំនួន ២២៣ ចំណែកឯ ខៀវ សំផន មានមូលដ្ឋាននៃបណ្ដឹងសាទុក្ខចំនួន ១៤៨[8]។ សហព្រះរាជអាជ្ញា ក៏បានជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ផងដែរ នៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០១៤ ប៉ុន្តែមានតែមូលដ្ឋានមួយប៉ុណ្ណោះ គឺថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសម្រេច ដោយពុំបានពិចារណាទៅលើទម្រង់ទី៣នៃសហឧក្រិដ្ឋកម្មរួម (“JCE III”) ថាជាទម្រង់នៃការទទួលខុសត្រូវមួយ[9]។

៥. នៅថ្ងៃទី២ និង ទី៦ ខែតុលា ឆ្នាំ ២០១៤ នួន ជា និង ខៀវ សំផន ស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រដើម្បីដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន[10]។ សហព្រះរាជអាជ្ញា ក៏បានស្នើសុំពន្យារពេលដើម្បីដាក់សារណាបណ្ដឹងសាទុក្ខផងដែរ និងស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រដើម្បីដាក់សារណាតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន[11]។ នៅថ្ងៃទី ៣១

---

[7] សាលក្រម ទំព័រ ៩៧៨-៩៧៩។

[8] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ឯកសារ E313/2/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ សូមមើលផងដែរ សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងសារណានៃបណ្ដឹងសាទុក្ខ ឯកសារ F3/3 ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤។

[9] សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ស្ដីពីបណ្ដឹងសាទុក្ខចំពោះសេចក្ដីសម្រេច នៅក្នុងសំណុំរឿង ០០២/០១ ឯកសារE313/3/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[10] សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F6 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤។ ការស្នើសុំជាបន្ទាន់របស់លោក ខៀវ សំផន សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រ នៅក្នុងសារណាបណ្ដឹងសាទុក្ខ ឯកសារ F7 ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤។

[11] ចម្លើយតប និងសំណើរបស់ព្រះរាជអាជ្ញាលើបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប ឯកសារ F7/1 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ (“ចម្លើយតប និងសំណើរបស់ ក.ស.ព សុំបន្ថែមចំនួនទំព័រ និងពេលវេលា”)។

ខែតុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូល បានទទួលយកផ្នែកខ្លះនៃសំណើដោយអនុញ្ញាតឲ្យ នួន ជា និង ខៀវ សំផន ដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួនត្រឹមថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៤ ពោលគឺ ចំនួន ៩០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ខ្លួន ជាភាសាអង់គ្លេស ឬ ភាសាបារាំង[12]។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់សារណាតបរួមមិនឲ្យលើសពី ២៨០ ទំព័រ ដែលត្រូវដាក់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយពេលដាក់សំណៅភាសាខ្មែរនៃសារណាបណ្ដឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន[13]។ អង្គជំនុំជម្រះតុលាការកំពូល ពុំបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាពន្យារពេលដាក់សារណាបណ្ដឹងសាទុក្ខឡើយ[14] ហើយសហព្រះរាជអាជ្ញា ក៏បានដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួនៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ("បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")[15]។

## សារណា

៦. ខៀវ សំផន ស្នើសុំការអនុញ្ញាតដាក់សារណាតបទៅនឹងសំណៅជាភាសាបារាំងនៃបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេល៣០ថ្ងៃក្រោយពេលដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន (ដែលគិតត្រឹមថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៤) ឬ ក្នុងរយៈពេល៣០ថ្ងៃនៃការដាក់ឯកសារបកប្រែជាភាសាបារាំងនៃបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រសិនបើឯកសារបកប្រែនេះ ពុំត្រូវបានដាក់នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤[16]។ ខៀវ សំផន សន្និដ្ឋានថា ការពន្យារពេលគឺជាការចាំបាច់ ដោយហេតុថាបញ្ហាដែលលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា មានលក្ខណៈស្មុគស្មាញ និងជាបញ្ហាមួយថ្មីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ហើយការពិតគឺថា គាត់ កំពុងតែរវល់ជាមួយនឹងការព្រាងសារណាបណ្ដឹងសាទុក្ខរបស់គាត់[17]។ នួន ជា ស្នើសុំការពន្យារពេល៣០ថ្ងៃ ប្រហាក់ប្រហែលគ្នានេះដែរ បន្ថែមទៅលើការដាក់សារណា

---

[12] សេចក្ដីសម្រេចលើសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប ឯកសារលេខ F9, ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៤ ("សេចក្ដីសម្រេចលើការពន្យារពេល និងបន្ថែមទំព័រលើបណ្ដឹងសាទុក្ខ"), កថាខណ្ឌ ២៣។

[13] សេចក្ដីសម្រេចលើសំណើសុំពន្យាររយៈពេល កថាខណ្ឌ ២៣។

[14] សេចក្ដីសម្រេចលើសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤។

[15] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ ០០២/០១ ឯកសារ F11 ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

[16] សំណើសុំពន្យារពេលរបស់ ខៀវ សំផន កថាខណ្ឌ ៧។

[17] សំណើសុំពន្យារពេលរបស់ ខៀវ សំផន កថាខណ្ឌ ៣។

បណ្តឹងសាទុក្ខរបស់ខ្លួន ដើម្បីដាក់សារណាតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដោយទទួលយកនូវតាមសំអាងហេតុរបស់ ខៀវ សំផន ដើម្បីគាំទ្រសំណើរបស់ខ្លួន បើទោះបីជាពុំមានលក្ខខណ្ឌនៃការបកប្រែភាសាបារាំងក៏ដោយ[18]។

៧. សហព្រះរាជអាជ្ញា ជឿជាក់ថា ការពន្យាពេល គឺជាការចាំបាច់ ហើយមិនទំទាស់ទៅនឹងសំណើរបស់ នួន ជា និង ខៀវ សំផន ដែលសុំពន្យារពេលចំនួន៣០ថ្ងៃ គិតចាប់ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ដើម្បីដាក់សារណាតបរបស់ខ្លួនឡើយ[19]។ ប៉ុន្តែ សហព្រះរាជអាជ្ញាបញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះតុលាការកំពូល គួរតែអនុញ្ញាតត្រឹមតែការពន្យារពេលសម្រាប់ ខៀវ សំផន ក្រោយពេលទទួលការបញ្ជាក់ជាលាយលក្ខណ៍អក្សរថា ខៀវ សំផន និងមេធាវីការពារក្តីរបស់គាត់ នឹងមិនប្រើប្រាស់ពេលវេលានេះ ដើម្បីបង្អាក់កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង០០២/០២ ឡើយ[20]។

៨. នួន ជា ក៏ស្នើសុំបន្ថែមចំនួន ៦០ទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនដែរ[21] ដោយបញ្ជាក់ថា គាត់ "សុំការធានា ក្នុងការកំណត់ទៅលើចំនួនទំព័រកំណត់នៃសារណារបស់ខ្លួនឲ្យបានខ្លីដែលធ្វើទៅបាន" បើទោះជា "សម្រេចចិត្តដកចេញនូវមូលដ្ឋានខ្លះនៃបណ្តឹងសាទុក្ខក្តី" ប៉ុន្តែថា "ដោយសារតែមិនមានការបន្ថែមចំនួនទំព័រ [គាត់] នឹងត្រូវបង្ខំឲ្យជ្រើសរើសរវាងការបោះបង់ចោលទឡ្ហីករណ៍បន្ថែម និងការលុបចោលនូវអំណះអំណាងសំខាន់ៗក្នុងការគាំទ្របណ្តឹងសាទុក្ខដែលខ្លួនរក្សាទុក"[22]។ គាត់លើកឡើងថា គាត់ "បានព្រាងភាគច្រើននៃសារណាបណ្តឹងសាទុក្ខរបស់[គាត់] [...] [ដែល] នៅពេលនេះ មានកម្រាស់ ២៣២ទំព័រ" ប៉ុន្តែថា "ទឡ្ហីករណ៍សំខាន់ៗនៃបណ្តឹងសាទុក្ខ កំពុងស្ថិតក្នុងការព្រាងនៅឡើយ" ដោយគាត់"រំពឹងថា ចំនួនទំព័រចុងក្រោយនឹងឡើងដល់ ២៨០ទំព័រ"[23]។

៩. សហព្រះរាជអាជ្ញាឆ្លើយតបថា សំណើរបស់ នួន ជា "ពុំមានអង្គហេតុ ឬអំណះអំណាងដែលពាក់ព័ន្ធថ្មី" និងថា "[ដូច្នេះ]គោលជំហររបស់សហព្រះរាជអាជ្ញា សូមរក្សានៅដដែល មិនផ្លាស់ប្តូរ

[18] សំណើសុំពន្យារពេលរបស់ នួន ជា កថាខណ្ឌ ៣-៤។

[19] សារណាតបរបស់ ក.ស.ព ទៅនឹងសំណើសុំពន្យារពេល កថាខណ្ឌ ២, ៥(ក)។

[20] សារណាតបរបស់ ក.ស.ព ទៅនឹងសំណើសុំពន្យារពេល កថាខណ្ឌ ៣-៤, ៥(ខ)។

[21] សំណើរបស់ នួន ជា សុំបន្ថែមចំនួនទំព័រ កថាខណ្ឌ ៥។

[22] សំណើរបស់ នួន ជា សុំបន្ថែមចំនួនទំព័រ កថាខណ្ឌ ២។

[23] សំណើរបស់ នួន ជា សុំបន្ថែមចំនួនទំព័រ កថាខណ្ឌ ៥។

ដូចបានជម្រាបជូនតាមរយៈសារណាតបចុងក្រោយរបស់ខ្លួន ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៤”[24]។ សហព្រះរាជអាជ្ញាថ្លែង នៅពេលនោះថា “ទោះបីជា [...] ក្រុមមេធាវីការពារក្តីមួយក្រុមៗ មានទំព័រកំណត់មួយសមហេតុផលចំនួន ១៥០ ទំព័រ ជាភាសាបារាំង ឬអង់គ្លេសក៏ដោយ ក៏សហព្រះរាជអាជ្ញា មិនជំទាស់ទៅនឹងការបន្ថែមចំនួនទំព័ររហូតដល់ទៅ ២០០ ទំព័រដែរ”[25]។

## ច្បាប់ជាធរមាន

១០. មាត្រា៨.៣ នៃសេចក្តីណែនាំអនុវត្ត[26]ចែងថា សារណាតបណាមួយទៅនឹងពាក្យសុំឬសារណា ត្រូវ ដាក់រួមជាមួយបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលប្រើប្រាស់ជាឯកសារយោងនៅក្នុងរយៈពេល ១០ (ដប់ថ្ងៃ)ថ្ងៃនៃប្រតិទិនគិតពីថ្ងៃជូនដំណឹងនៃឯកសារដែលត្រូវឆ្លើយតប។ អនុលោមតាមមាត្រា ៥.២ នៃសេចក្តីណែនាំអនុវត្ត ឯកសារដាក់នៅអង្គជំនុំជម្រះតុលាការកំពូល មិនត្រូវលើសពី៣០ទំព័រជាភាសាអង់គ្លេស ឬ បារាំង ឬ៦០ទំព័រជាភាសាខ្មែរ។ វិធាន ៣៩(២) នៃវិធានផ្ទៃក្នុង[27] មើលឃើញជាមុនរួចទៅហើយ ដោយចែងថា លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង ចៅក្រមអាចកំណត់ពេលវេលាសម្រាប់ដាក់សារណា សេចក្តីសន្និដ្ឋាន និងឯកសារ ពាក់ព័ន្ធទៅនឹងសំណើសុំណាមួយ ឬបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ។ វិធាន ៣៩(៤)នៃវិធាន ផ្ទៃក្នុង ក៏ផ្តល់អំណាចដល់ ចៅក្រមក្នុងការ “ពន្យារពេលវេលាកំណត់ដែលខ្លួនបានកំណត់” ឬ “ទទួលស្គាល់ថាមានសុពលភាពចំពោះកិច្ចទាំងឡាយណា ដែលបានធ្វើក្រោយពីពេលកំណត់ដែល មានចែងក្នុងវិធានផ្ទៃក្នុងនេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល”[28]។ មាត្រា៥.៤ នៃសេចក្តីណែនាំអនុវត្តចែងបន្ថែមទៀតថា តាមការស្នើសុំរបស់ភាគីចូលរួមអង្គជំនុំជម្រះដែលពាក់ព័ន្ធ អាចបង្កើនចំនួនសន្លឹករបស់ឯកសារនៅក្នុងកាលៈទេសៈពិសេស។

[24] សារណាតបរបស់ ក.ស.ព ទៅនឹងសំណើសុំបន្ថែមចំនួនទំព័រ កថាខណ្ឌ ១។

[25] សារណាតប និងសំណើរបស់ ក.ស.ព សុំបន្ថែមចំនួនទំព័រ និងពេលវេលា កថាខណ្ឌ ១៣។

[26] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក វិសោធនកម្មលើកទី ៨ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១២ (“សេចក្តីណែនាំអនុវត្ត”)។

[27] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក វិសោធនកម្មលើកទី ៨ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១ (“វិធានផ្ទៃក្នុង”)។

[28] សូមមើលផងដែរ មាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្ត។

## ការពិភាក្សា

### សំណើសុំពន្យារពេលដើម្បីឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

១១. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា គឺស្ថិតនៅក្នុងការកំណត់ទំព័រតាមច្បាប់សម្រាប់ការដាក់ជាឯកសារ គឺ ២៩ទំព័រ និងដោះស្រាយលើបញ្ហាតែមួយប៉ុណ្ណោះ ពោលគឺ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឆ្នាំ ២០១១ ដោយពុំបានពិចារណាទៅលើសហឧក្រិដ្ឋកម្មទម្រង់ទី ៣ ថាជាទម្រង់នៃការទទួលខុសត្រូវមួយ[29] ដែល នួន ជា ទទួលស្គាល់ថាចំណុចនេះ ត្រូវបាន"ប្ដឹងចំនួនពីរដងរួចមកហើយនៅក្នុងតុលាការនេះ"[30]។ ជាការពិតណាស់ នួន ជា និង ខៀវ សំផន សុទ្ធតែបានដាក់សារណាជាលាយលក្ខណ៍អក្សរលើចំណុចនេះនៅពេលសវនាការ ដែលជំទាស់ទៅនឹងបំណងរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូល JCE III ក្នុងសំណុំរឿង ០០២[31] ហើយពួកគេបានទទួលផលប្រយោជន៍ពីសារណាស្រដៀងគ្នានេះ ដែលធ្វើឡើងដំណាលទៅនឹងសារណារបស់អៀង សារី និង អៀង ធីរិទ្ធ[32]។ ខៀវ សំផន អៀង សារី និង អៀង ធីរិទ្ធ ក៏បានដាក់សារណាជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយជំទាស់ទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដែលសម្រេចថា សហឧក្រិដ្ឋកម្មរួម អាចអនុវត្តក្នុងទម្រង់ទាំងបី នៅចំពោះមុខ អ.វ.ត.ក[33] ដែលចំណុចនេះ ត្រូវបានអង្គបុរេជំនុំជម្រះ

[29] សេចក្ដីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ឯកសារ E100/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១។

[30] សំណើរបស់ នួន ជា សុំបន្ថែមចំនួនទំព័រ កថាខណ្ឌ ៣។

[31] សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុក JCE III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសមួយផ្សេងទៀត ឯកសារ E100/5 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងទម្រង់ទី ៣ នៃសហឧក្រិដ្ឋកម្មរួម ឯកសារ E100/3 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

[32] សារណាតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ជាទម្រង់មួយទៀតនៃការទទួលខុសត្រូវ និងសំណើសុំឱ្យមានសវនាការផ្ទាល់មាត់ដើម្បីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ឯកសារ E100/2 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់មេធាវីការពារក្ដីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត ឯកសារ E100/1 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

[33] ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ឯកសារ D97/13 ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩។ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការដាក់ឱ្យអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថា "សហឧក្រិដ្ឋកម្មរួម" ឯកសារ D97/16/1 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ

បដិសេធផ្នែកខ្លះ ដោយសម្រេចថា JCE III មិនមែនជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិឡើយ នៅក្នុងរយៈកាលនៃយុត្តាធិកាពេលវេលារបស់ អ.វ.ត.ក[34]។ ដោយហេតុដូច្នេះ នួន ជា និង ខៀវ សំផន ពិតជាបានយល់ដឹងច្បាស់ និងបានរៀបចំខ្លួនដើម្បីឆ្លើយតបទៅនឹងខ្លឹមសារនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាហើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល ពុំយល់ស្របតាមការលើកឡើងថាមានការស្មុគស្មាញ ឬភាពថ្មី ដើម្បីធ្វើយុត្តិកម្មចំពោះការពន្យារពេលឡើយ។

១២. ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ការកំណត់ពេលវេលា១០ថ្ងៃ គិតចាប់ពីការជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា សម្រាប់ការដាក់សារណាតប ដោយអនុលោមតាមមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្ត នឹងអាចតម្រូវឱ្យ នួន ជា និង ខៀវ សំផន បង្វែរការយកចិត្តទុកដាក់ចេញពីសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ដែលនឹងដល់ពេលកំណត់នៅចុងខែនេះ។

១៣. ដោយពិចារណាទៅលើសារៈសំខាន់នៃសារណាបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការសមស្រប ក្នុងការអនុញ្ញាតតាមសំណើរបស់ នួន ជា និង ខៀវ សំផន ក្នុងការដាក់សារណាតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួននៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៤។ ដោយពិចារណាបន្ថែមទៀតថា ការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២ នឹងត្រូវបានបន្តនៅថ្ងៃទី ៨ ខែមករា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលរំពឹងថា ការអនុញ្ញាតផ្តល់ពេលវេលាបន្ថែមនេះ មានលក្ខណៈគ្រប់គ្រាន់ ដើម្បីអាចធ្វើការសម្របសម្រួលកាតព្វកិច្ចរបស់ជនជាប់ចោទចំពោះការជំនុំជម្រះក្តីដែលកំពុងតែបន្តនោះ ជាពិសេសពាក់ព័ន្ធទៅនឹងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២។ ជាសន្និដ្ឋាន នួន ជា និង ខៀវ សំផន អាចដាក់សារណាតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាត្រឹម ថ្ងៃពុធ ទី ២៨ ខែមករា

---

២០១០ (សម្ងាត់)។ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ ចំពោះ "ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ D97/15/1 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០ ឯកសារ D97/14/5 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០។

34 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ឯកសារ D97/15/9 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០។

ឆ្នាំ ២០១៥[35]។

១៤. ចំពោះសំណើរបស់ ខៀវ សំផន ដែលត្រូវដាក់ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីពេលដាក់ឯកសារជាភាសាបារាំងនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងករណីដែល សំណើនេះ ត្រូវដាក់បន្ទាប់ពីថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលរំលឹកឡើងវិញថា ភាសាផ្លូវការរបស់ អ.វ.ត.ក គឺភាសាខ្មែរ អង់គ្លេស និងបារាំង[36] ហើយរាល់ឯកសារទាំងអស់នៅចំពោះមុខ អ.វ.ត.ក ត្រូវតែដាក់ជាភាសាខ្មែររួមជាមួយភាសាអង់គ្លេស និង/ឬបារាំង[37] ដែលពេលវេលាកំណត់ ត្រូវចាប់ផ្តើមគិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃដាក់ឯកសារទាំងនេះ[38]។ មាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្ត ចែងថា ក្នុងករណីពិសេស "អង្គជំនុំជម្រះ អាចសម្រេចថា ពេល វេលាកំណត់ ត្រូវចាប់ផ្តើមគិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃដាក់ឯកសារជាបីភាសាផ្លូវការ"។ ខៀវ សំផន ពុំបានលើកហេតុផលគាំទ្រសំណើរបស់ខ្លួន ដែលទោះក្នុងកាលៈទេសៈណាក៏ដោយ ពុំទាន់ដល់ពេលសមស្របនោះទេ ដើម្បីអាចទទួលបានផលប្រយោជន៍ពីករណីពិសេស ដែលមានចែងក្នុងមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តនេះ។ អាស្រ័យហេតុនេះ សំណើនេះត្រូវបានបដិសេធចោល ជាអសារបង់។

## ***<u>សំណើសុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខរបស់ នួន ជា</u>***

១៥. អង្គជំនុំជម្រះតុលាការកំពូលរំលឹកនូវការសម្រេចរបស់ខ្លួនកាលពីពេលកន្លងទៅថា ការកម្រិតត្រឹម ២១០ ទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន និង ២៨០ទំព័រសម្រាប់

[35] ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ខៀវ សំផន និងក្រុមមេធាវីរបស់ខ្លួន ទំនងជាជួបបញ្ហានៃបន្ទុកការងារ ដូចដែលបានបង្ហាញតាមរយៈការបដិសេធមិនចូលរួមកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ក្នុងសំណុំរឿង ០០២/០២ រហូតទាល់តែដល់ពេលដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន។ *សូមមើល* សេចក្តីសម្រេចលើការចាត់តាំងមេធាវីរបស់តុលាការសម្រាប់ ខៀវ សំផន ឯកសារ E320/2 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៤ កថាខណ្ឌ ១ ដល់ ១០, សេចក្តីយោងដកស្រង់នៅទីនោះ។ *សូមមើល* អនុស្សរណៈរបស់ចៅក្រម និល នុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ការប្រមានដល់មេធាវីការពារក្តី នួន ជា និង ខៀវ សំផន" ឯកសារ E320 ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១។

[36] មាត្រា ៤៥ ថ្មីនៃច្បាប់ស្តីពីការបង្កើត អវតក ដែលត្រូវបានអនុម័តនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់របស់ អ.វ.ត.ក")។

[37] មាត្រា ៧.១ នៃសេចក្តីណែនាំអនុវត្ត (សេចក្តីបញ្ជាក់បន្ថែម)។

[38] មាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្ត។

សារណាតបរួមរបស់សហព្រះរាជអាជ្ញា មានលក្ខណៈសមស្រប នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ[39]។ ទោះជាយ៉ាងណាក្តី ការកម្រិតបែបនេះ ត្រូវតែធ្វើឡើងដោយស្របទៅនឹងតម្រូវការចាំបាច់របស់ភាគី ដើម្បីឲ្យមានតុល្យភាពជាមួយនឹងគោលការណ៍ប្រសិទ្ធភាពរបស់តុលាការ[40]។

១៦. អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ចំនួន ២១០ទំព័រ គឺជាការសមស្របសម្រាប់ នួន ជា ដែលមានទទ្បីករណ៍បណ្តឹងសាទុក្ខចំនួន២២៣ ព្រមទាំងការសម្រេចខុសៗគ្នាចំនួន ១៦ របស់អង្គជំនុំជម្រះសាលាដំបូងដែល នួន ជា បានបង្ហាញពីគោលបំណងចង់ធ្វើការជំទាស់។ បច្ចុប្បន្ន នួន ជា បង្ហាញថា គាត់បានសម្រេចចិត្តដកចេញនូវមូលដ្ឋានខ្លះៗនៃបណ្តឹងសាទុក្ខ ប៉ុន្តែទោះជាយ៉ាងណាក្តី ក៏តម្រូវចំនួន៦០ទំព័របន្ថែម ដើម្បីផ្តល់ទទ្បីករណ៍ឲ្យបានពេញលេញគ្រប់ជ្រុងជ្រោយនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សារណាចុងក្រោយរបស់ នួន ជា មានសំអាងហេតុត្រឹមត្រូវគ្រប់គ្រាន់ ក្នុងការទទួលបាននូវការផ្តល់ចំនួនទំព័របន្ថែម។

[39] សេចក្តីសម្រេចលើសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខ កថាខណ្ឌ ១៧។

[40] សូមមើល សេចក្តីសម្រេចលើសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខ កថាខណ្ឌ ១៥-១៧។

## <u>ផ្នែកសម្រេចសេចក្តី</u>

១៧. យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ**

**ទទួលយក** ផ្នែកខ្លះនៃសំណើ។

**អនុញ្ញាតឲ្យ** នួន ជា ដាក់សារណាបណ្តឹងសាទុក្ខមិនឲ្យលើសពី២៧០ទំព័រជាភាសាអង់គ្លេស ហើយឯកសារបកប្រែជាភាសាខ្មែរត្រូវតែសមមូលទៅនឹងចំនួននេះ និង,

**អនុញ្ញាតឲ្យ** នួន ជា និង ខៀវ សំផន ដាក់សារណាតបរៀងៗខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ត្រឹមថ្ងៃពុធ ទី ២៨ ខែមករា ឆ្នាំ ២០១៥។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

គង់ ស្រឹម